# បទពិសោធន៍ការចិញ្ចឹមអន្ទង់
# ជាលក្ខណៈគ្រួសារនៅខេត្តបាត់ដំបង





ខណ្ឌរដ្ឋបាលជលផល បាត់ដំបង

**Battambang Fisheries Administration Cantonment**

ឆ្នាំ ២០១០

# បទពិសោធន៍ការចិញ្ចឹមអន្ទង់
# ជាលក្ខណៈគ្រួសារនៅខេត្តបាត់ដំបង


**ស្រាវជ្រាវ និងចងក្រងដោយៈ**

**លោក ហេង ពិសិដ្ឋ** នាយខណ្ឌរដ្ឋបាលជលផល បាត់ដំបង

**លោក កក អ៊ីឡូន** នាយផ្នែករដ្ឋបាលជលផល ព្រែកទាល់

**ពិនិត្យ និងកែសម្រួលដោយៈ**

**ឯកឧត្តម ណៅ ធូក** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា ប្រធានរដ្ឋបាលជលផល

**ឯកឧត្តម សម នៅ** អគ្គនាយករង នៃរដ្ឋបាលជលផល

**ឯកឧត្តម ស្រ៊ុន លឹមសុង** អគ្គនាយករង នៃរដ្ឋបាលជលផល

**មន្ត្រីបច្ចេកទេស** នាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម



**រក្សាសិទ្ធិដោយៈ**

**ខណ្ឌរដ្ឋបាលជលផល បាត់ដំបង**

# អារម្ភកថា

ប្រិយមិត្តអ្នកអានជាទីមេត្រី! ពេលដែលលោកអ្នកបានចាប់យកសៀវភៅនេះមកអានយើងខ្ញុំយល់ថា លោកអ្នក ប្រហែលជាអ្នកដែលចូលចិត្តពិសាសាច់អន្ទង់ ឬ យ៉ាងហោចណាស់ក៏អាចជាអ្នកដែលមានបំណងចង់ចូលរួមក្នុងការចិញ្ចឹម ឬ ចង់ពង្រីកសកម្ម-ភាពអភិវឌ្ឍការចិញ្ចឹមអន្ទង់ក្នុងកសិដ្ឋានរបស់ខ្លួនផងដែរ។ ព្រោះថាអន្ទង់កំពុងមានតម្លៃសេដ្ឋកិច្ចខ្ពស់នៅលើទីផ្សារ ដោយសារបានទទួលការពេញនិយមក្នុងការបរិភោគពីអ្នកប្រើប្រាស់ដែលបានចាត់ទុកថា សាច់អន្ទង់ជាធាតុផ្សំមុខម្ហូបបានច្រើនយ៉ាង និងមានឱជារសឆ្ងាញ់ពិសា។ កន្លងមកយើងបានសង្កេតឃើញថា មានចលនាចិញ្ចឹមអន្ទង់នៅតំបន់មួយចំនួន ដើម្បីរួមចំណែកផ្គត់ផ្គង់តម្រូវការលើទីផ្សារ ប៉ុន្តែអ្នកចិញ្ចឹមមួយចំនួនទទួលបានជោគជ័យ និងមួយចំនួនទៀត ទទួលបានត្រឹមតែបទពិសោធន៍ប៉ុណ្ណោះ។ អាស្រ័យហេតុនេះហើយ ទើបយើងខ្ញុំបានខិតខំប្រមូលព័ត៌មានពីបទពិសោធន៍ នៃការចិញ្ចឹមអន្ទង់ពីកសិករឈ្មោះ **ខឹម សារិទ្ធ** ភូមិរហាលស្លួង ឃុំព្រៃកន្ទិរ ស្រុកឯកភ្នំ ខេត្តបាត់ដំបងដែលបានឆ្លងកាត់បទពិសោធន៍ការចិញ្ចឹមអន្ទង់ក្នុងអាងប្លាស្ទិចរយៈពេលបួនឆ្នាំ ហើយទទួលបានជោគជ័យជាបន្តបន្ទាប់មកចងក្រងជាឯកសារសម្រាប់ជាមូលដ្ឋានក្នុងការសិក្សាស្រាវជ្រាវបន្ត និងជាការបង្ហាញផ្លូវសម្រាប់ជួយឱ្យកសិករ ដែលមានបំណងចង់សាកល្បងចិញ្ចឹមអន្ទង់។

ឯកសារនេះត្រូវបានចងក្រងឡើង ដោយបានសម្រង់យកបទពិសោធន៍តាមរយៈឯកសារ ដែលអ្នកស្រាវជ្រាវបានចងក្រងកន្លងមក និងព័ត៌មានដែលប្រមូលបានពីកសិករកំពុងអនុវត្តផ្ទាល់។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ជូនចំពោះឯកឧត្តម **ណៅ ធួក** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា ប្រធានរដ្ឋបាលជលផល ទោះបីជាឯកឧត្តមមាន

ការមមាញឹកក្នុងការដឹកនាំអភិវឌ្ឍន៍វិស័យជលផលក៏ដោយ ក៏ឯកឧត្តមបានចូលរួមដឹកនាំអនុវត្តដោយផ្ទាល់ និងយ៉ាងសស្រាក់សស្រាំ ក្នុងការជួយផ្តល់ជាមតិល្អៗ ដើម្បីរៀបចំស្រាវជ្រាវចងក្រង និងកែសម្រួលអត្ថបទនេះឱ្យកាន់តែមានអត្ថន័យ និងប្រកបដោយខ្លឹមសារគ្រប់គ្រាន់។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ជូនចំពោះឯកឧត្តម **សម នៅ** និងឯកឧត្តម **ស្រ៊ុន លឹមសុង** អគ្គនាយករង នៃរដ្ឋបាលជលផល ដែលបានចូលរួមគាំទ្រយ៉ាងសស្រាក់សស្រាំក្នុងនាមគ្រួសារតែមួយ ដើម្បីសម្រេចនូវអនុសាសន៍ដ៏ឧត្តុង្គឧត្តមរបស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាលកម្ពុជា និងទស្សនវិស័យរបស់រដ្ឋបាលជលផល និងបានជួយផ្តល់មតិល្អៗក្នុងការកែសម្រួលអត្ថបទនេះ ប្រកបដោយអត្ថន័យ និងអត្ថរស។

សូមថ្លែងអំណរគុណជាអតិបរមា ចំពោះលោក **ខឹម សារិទ្ធ** ប្រធានសហគមន៍នេសាទរហាលសួង និងជាអ្នកមានបទពិសោធន៍ចិញ្ចឹមអន្ទង់ ព្រមទាំងសហការីដែលបានផ្តល់ព័ត៌មាន និងបទពិសោធន៍ពីការចិញ្ចឹមអន្ទង់សម្រាប់រៀបចំចងក្រងឯកសារនេះឡើង ដើម្បីជាត្រីវិស័យសម្រាប់កសិករដែលមានការចាប់អារម្មណ៍ចង់សិក្សាស្រាវជ្រាវចិញ្ចឹមបន្ត។

យើងខ្ញុំសូមការយោគយល់អធ្យាស្រ័យរាល់កំហុសឆ្គង និងការខ្វះចន្លោះទាំងឡាយដែលមានក្នុងសៀវភៅនេះ យើងខ្ញុំរងចាំទទួលយកនូវការរិះគន់ កែលំអទាំងឡាយ ដើម្បីធ្វើឱ្យឯកសារនេះក្លាយជាប្រទីបមួយប្រកបដោយប្រសិទ្ធភាពក្នុងការចិញ្ចឹមអន្ទង់ឱ្យកាន់តែផុលផុស។

# មាតិកាអត្ថបទ


១- ប្រភេទអន្ទង់............................................................................១

ក. អន្ទង់ត្រាវ............................................................................១

ខ. អន្ទង់ដំណើប............................................................................១

គ. អន្ទង់ត្រាវ............................................................................១

២- ការចិញ្ចឹមអន្ទង់............................................................................២

៣- ការរៀបចំអាង............................................................................៣

ក. សម្ភារះរួមផ្សំ............................................................................៣

ខ. ការសាងសង់អាងប្លាស្ទិក............................................................................៤

៤- ប្រភពពូជកូនអន្ទង់ ............................................................................៥

៥- ការលែងកូនអន្ទង់ពូជ............................................................................៥

ក. ការជ្រើសរើសកូនអន្ទង់ពូជ............................................................................៥

ខ. ប្រភេទអន្ទង់............................................................................៦

គ. ដង់ស៊ីតេដាក់ចិញ្ចឹម............................................................................៧

ឃ. ការដឹកជញ្ជូន និងពេលវេលាលែងកូនអន្ទង់............................................................................៧

៦- ពេលវេលាដាក់ចិញ្ចឹម............................................................................៨

៧- ប្រភេទចំណីអន្ទង់............................................................................៨

ក. ប្រភេទចំណី............................................................................៩

ខ. ចរិតស៊ីចំណី............................................................................១០

គ. ពេលវេលាផ្តល់ចំណី............................................................................១១

ឃ. របៀបផ្តល់ចំណី............................................................................១១

៨- ការតាមដានគុណភាពទឹក និងការផ្លាស់ប្តូរទឹក..................................................១២
៩- ជំងឺអន្ទង់..........................................................................................................១៣
១០- ការប្រមូលផល...............................................................................................១៣
១១- ការវិភាគសេដ្ឋកិច្ច.........................................................................................១៣
១២- ការសន្និដ្ឋាន.................................................................................................១៦

## ១~ ប្រភេទអន្ទង់

អន្ទង់មានច្រើនប្រភេទ ហើយត្រូវបានគេចិញ្ចឹមតាមអាងស៊ីម៉ងត៍ ឬ អាងធ្វើពីស៊ុមឈើព័ទ្ធជុំវិញ ដាក់ផ្ទាំងកៅស៊ូក្រាលពីក្នុង អាស្រ័យទៅតាមលទ្ធភាពរបស់អ្នកចិញ្ចឹមម្នាក់ៗ។ ដោយឡែកក្នុងករណីសិក្សានៅខេត្តបាត់ដំបង អន្ទង់មានបីប្រភេទគឺ អន្ទង់ត្រាវ អន្ទង់ដំណើប និងអន្ទង់ព្រ័ត្រ។ អន្ទង់ដែលអ្នកប្រើប្រាស់បានចាត់ទុកថាមានរសជាតិជាងគេគឺ អន្ទង់ដំណើប និងអន្ទង់ត្រាវ ហើយអន្ទង់ដែលចិញ្ចឹមឆាប់ធំជាងគេគឺ អន្ទង់ត្រាវ។

លក្ខណៈរូបរាងខាងក្រៅអន្ទង់ទាំងបីប្រភេទនេះ មានដូចខាងក្រោមៈ

**ក-អន្ទង់ត្រាវៈ** ក្បាលមានទំហំតូចជាងខ្លួន ហើយចាប់ពីផ្នែកកមកដងខ្លួនមានរាងស្តួចមកផ្នែកកន្ទុយ។ ផ្នែកពោះមានពណ៌សលាយពណ៌លឿងព្រឿងៗ និងមានអុចៗពណ៌ខ្មៅ និងនៅផ្នែកខ្នងមានពណ៌ត្នោត។ ពេលត្រូវកំដៅភ្លើង (ចំអិន) ស្បែករបស់វានឹងប្រេះជាច្រើនកន្លែង ហើយឃើញសាច់ខាងក្នុង។ អន្ទង់ត្រាវតូចជាងអន្ទង់ដំណើប។ អន្ទង់ប្រភេទនេះ សម្បូរនៅតាមទំនាបនៃតំបន់បឹងទន្លេសាប និងបឹងបួនានាក្នុងទូទាំងប្រទេស ។

**ខ-អន្ទង់ដំណើបៈ** ក្បាលមានទំហំធំជាងដងខ្លួន ហើយចាប់ពីផ្នែកកមកដងខ្លួនមានរាងស្តួចមកផ្នែកកន្ទុយ។ ផ្នែកពោះមានពណ៌ក្រហមព្រឿងៗមិនមានចំណុចអុចៗទេ និងនៅផ្នែកខ្នងមានពណ៌ក្រហមព្រឿងបែបស្លាទុំ។ ពេលត្រូវកំដៅភ្លើង(ចំអិន) ស្បែករបស់វាស្ទិតរួញទៅនឹងដងខ្លួន មិនប្រេះដូចអន្ទង់ត្រាវទេ។ អន្ទង់ប្រភេទនេះសម្បូរនៅតាមទំនាបនៃតំបន់បឹងទន្លេសាប និងបឹងបួនានាក្នុងទូទាំងប្រទេស ។

**គ-អន្ទង់ព្រ័ត្រៈ** រូបរាងដូចរូបភាពខាងក្រោម ផ្នែកខ្នងមានពណ៌ខ្មៅដូចស្លាបក្អែក និងនៅផ្នែកពោះមានពណ៌ខ្មៅ រាងស្វាយរលោង។ ក្បាលមានទំហំតូចជាងដងខ្លួន

ហើយចាប់ពីផ្នែកកមកដងខ្លួនមានរាងស្តួចមកផ្នែកកន្ទុយ ។ ពេលត្រូវកំដៅភ្លើង(ចំអិន) ស្បែករបស់វាស្វិតរួញទៅនឹងដងខ្លួនមិនប្រេះដូចអន្ទង់ត្រាវទេ ។ បើប្រៀបធៀបទម្ងន់ដូចគ្នា អន្ទង់ព្រ័ត្រមានប្រវែងវែងជាងអន្ទង់ត្រាវ និងដំណើប ។ អន្ទង់ប្រភេទនេះសម្បូរនៅតំបន់បឹងទន្លេសាប ។



*អន្ទង់ត្រាវ* *អន្ទង់ដំណើប* *អន្ទង់ព្រ័ត្រ*

## ២_ ការចិញ្ចឹមអន្ទង់

ដោយសារកំណើននៃតម្រូវការអន្ទង់នៅលើទីផ្សារ ក៏ដូចជានៅតាមភោជនីយ-ដ្ឋាននានាបានធ្វើឱ្យប្រជានេសាទ និងប្រជាកសិករព្យាយាមស្វែងយល់ពីបច្ចេកទេសថែបំប៉ន ឬ ចិញ្ចឹមប្រភេទអន្ទង់ទាំងនេះ ដើម្បីទុកលក់នៅរដូវដែលអន្ទង់មានតម្លៃខ្ពស់ ។ តាមការសិក្សាស្រាវជ្រាវកន្លងមកបានបង្ហាញថា សកម្មភាពចិញ្ចឹមអន្ទង់មានរូបភាពពីរ គឺចិញ្ចឹមក្នុងទ្រុង បែ ឬ ត្រើង និងចិញ្ចឹមក្នុងអាងតូចៗក្រាលប្លាស្ទិក ឬ អាងធ្វើពីស៊ីម៉ងត៍ ដូចរូបភាពខាងក្រោម ។ ការចិញ្ចឹមអន្ទង់តាមទ្រុង បែ ឬ ត្រើង ច្រើនអនុវត្តនៅតាមភូមិសាស្ត្រដែលមានទឹកលិចជាប្រចាំ ។ ចំណែកការចិញ្ចឹមអន្ទង់ក្នុងអាងតូចៗអាចអនុវត្ត

បានគ្រប់ទីកន្លែង ។ ក៏ប៉ុន្តែឯកសារនេះ រៀបរាប់តែការចិញ្ចឹមក្នុងអាងប្លាស្ទិកតែប៉ុណ្ណោះ ។



ចិញ្ចឹមអន្ទង់ក្នុងអាងស៊ីម៉ង់ត៍



ចិញ្ចឹមអន្ទង់ក្នុងអាងប្លាស្ទិក



ចិញ្ចឹមអន្ទង់ក្នុងគ្រឹង

## ៣~ ការរៀបចំអាង

### ក -សម្ភារះរួមផ្សំ

- ដើម្បីសង់អាងចិញ្ចឹមអន្ទង់ ចាំបាច់ត្រូវមានសម្ភារៈមួយចំនួនដូចជា បង្គោលឈើ របាឈើ បន្ទះព្រួល កម្រាលប្លាស្ទិក (ក្រាស់) ស្បៃនីឡុងក្រឡាញឹក ខ្សែនីឡុង ឬលួសចំណង ដែកគោល និងទុយោ ។
- ទំហំអាងដែលមានលក្ខណៈសមស្របគឺ បណ្ដោយ ៥ ម៉ែត្រ ទទឹង ១,៥ ម៉ែត្រ និងកម្ពស់ ០,៧ ម៉ែត្រ ទៅតាមទីតាំង ឬ ទីធ្លាដីដែលយើងមាន ។
- វល្លិ៍ត្រើក និងមែកឈើ ដូចជាមែករាំង និងមែកត្រស់សម្រាប់រៀបចំជាជម្រកអន្ទង់ ។



វល្លិ៍ត្រើក



ការរៀបចំវល្លិ៍ត្រើក



មែករាំង



ការរៀបចំមែករាំង

## ៥-ការសាងសង់អាងប្លាស្ទិក

អាងចិញ្ចឹមអន្ទង់ត្រូវសង់ពីលើដីផ្ទាល់តែម្តង ដើម្បីងាយស្រួលក្នុងការបង្ហូរទឹកចេញនៅពេលត្រូវការប្តូរទឹកថ្មី។ ទីតាំងដែលត្រូវសាងសង់អាងគួរជ្រើសរើសយកក្បែរសំយាបផ្ទះ និងនៅពីក្រោមចុងទរទឹកដែលភ្ជាប់ពីដំបូលផ្ទះ ដើម្បីងាយស្រួលទទួលទឹកភ្លៀងបានច្រើននៅពេលមានភ្លៀងធ្លាក់ ដែលមានប្រយោជន៍នៅពេលចង់ធ្វើការផ្លាស់ប្តូរទឹកក្នុងអាង និងទីតាំងអាងត្រូវស្ថិតនៅក្នុងម្លប់មិនទទួលរងកំដៅថ្ងៃខ្លាំងពេក។

បង្គោលឈើត្រូវដាក់ចូលទៅក្នុងដី ចន្លោះពីមួយទៅមួយចម្ងាយ ០,៨ ម៉ែត្រទៅ ១ ម៉ែត្រ និងដាក់របានៅផ្នែកខាងក្នុងអាងចន្លោះពីគ្នា ០,៣ ម៉ែត្រ ទៅ ០,៤ ម៉ែត្រ។ បន្ទាប់មកយើងចាប់ផ្តើមក្រាលព្រួលបញ្ឈរ ដោយចងភ្ជាប់នឹងរបារួចរៀបស្បៃនីឡុងក្រឡាញឹក ពាសកម្រាលកៅស៊ូតាមជញ្ជាំងព្រួល និងបាតក្រោមរួមគ្នាតែម្តង។ បំពង់បង្ហូរទឹកចេញត្រូវដាក់យ៉ាងតិចពីរនៅតាមជ្រុងនៃអាង ដើម្បីងាយស្រួលបង្ហូរទឹកចេញ។ ការរៀបចំចិញ្ចឹមអន្ទង់នៅក្នុងអាងត្រូវធ្វើឡើង ដោយផ្អែកលើលក្ខណៈធម្មជាតិដែលអន្ទង់ធ្លាប់រស់នៅ ហើយត្រូវរៀបចំឱ្យមានសំបុកសម្រាប់ធ្វើជាជម្រក និងដើម្បីផ្សាំទៅនឹងជីវិតជាក់ស្តែងរបស់វាដែលរស់នៅក្នុងធម្មជាតិ។ តាមការអនុវត្តរបស់អ្នកចិញ្ចឹមអន្ទង់ ការរៀបចំសំបុកសម្រាប់ជាជម្រកអន្ទង់គឺ ប្រើវល្លិ៍ត្រើក ដែលត្រូវហាលថ្ងៃឱ្យស្រពាប់ពណ៌ក្រហមព្រឿងៗ (មួយអាទិត្យ) រួចត្រាំទឹកឱ្យរលួយ (រយៈពេលយ៉ាងតិចមួយសប្តាហ៍) ទើបយកមកដាក់ក្នុងអាង និងត្រូវដាក់មែកឈើមួយចំនួនទៀតដូចជាមែករាំង មែកត្រស់ ដែលត្រូវត្រាំទឹក (រយៈពេលយ៉ាងតិចមួយសប្តាហ៍)។ វល្លិ៍ត្រើកត្រូវតម្រៀបពីក្រោម ហើយដាក់មែកឈើពីលើដើម្បីឱ្យអន្ទង់វារតោង សម្រាក ឬ ស៊ីចំណី ។

សូមបញ្ជាក់ថាការចិញ្ចឹមនេះ ពុំមានប្រើប្រាស់ដីភក់ ឬ ដើមចេក ឬលាមកសត្វស្បែកសត្វ ឬ ចំបើង ដូចមានសរសេរក្នុងឯកសារមួយចំនួននោះទេ។ រួចបញ្ចូលទឹកក្នុង

អាងឱ្យមានកម្ពស់ ០,៧ ម៉ែត្រ រយៈពេលយ៉ាងតិច ១០ថ្ងៃ មុនពេលលែងកូនអន្ទង់ក្នុងអាង និងត្រូវបញ្ចូលទឹកចុះឡើងក្នុងអាងធ្វើយ៉ាងណាឱ្យទឹកបាត់ក្លិនស្អុយដោយសារវល្លិ៍ត្អើក និងមែកឈើសិន។ កំប្លោក ឬ ចក មិនមែនជារុក្ខជាតិចាំបាច់ត្រូវតែដាក់នោះទេ ក៏ប៉ុន្តែគេអាចដាក់កំប្លោកជាជម្រកបាន គឺមិនត្រូវដាក់ឱ្យលើសពី ១/៤ (មួយភាគបួន) នៃផ្ទៃអាងឡើយ។


*គ្រោងឆ្អឹងអាង*


*ការពាសកម្រាលកៅស៊ូ*


*ការពាសស្បៃមុង*


*បំពង់បង្ហូរទឹកចេញ*

## ៤~ ប្រភពកូនពូជអន្ទង់

បច្ចុប្បន្ននេះ កូនពូជអន្ទង់ដែលយកមកចិញ្ចឹម គឺទទួលបានពីធម្មជាតិទាំងស្រុង ដោយមិនទាន់មានសមត្ថភាពភ្ញាស់នៅឡើយ ក៏ប៉ុន្តែរដ្ឋបាលជលផលកំពុងតែខិតខំស្រាវ-ជ្រាវលើផ្នែកបង្កាត់ភ្ញាស់កូនអន្ទង់ពូជ នៅតាមស្ថានីយ៍នានាក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីចែកចាយឱ្យបានសមស្របតាមតម្រូវការរបស់កសិករ និងកាត់បន្ថយសម្ពាធលើការចាប់អន្ទង់ក្នុងធម្មជាតិមកចិញ្ចឹម។

## ៥~ ការលែងកូនអន្ទង់ពូជ

### ក- ការជ្រើសរើសកូនអន្ទង់ពូជ

មិនខុសពីត្រីនោះទេ ការលែងកូនអន្ទង់ពូជដែលមានទំហំខុសគ្នាធ្វើឱ្យមានការប្រជែងគ្នាស៊ីចំណី និងបណ្តាលឱ្យការធំធាត់ក៏ខុសគ្នាដែរ។ យើងត្រូវដឹងដែរថាអន្ទង់

ជាប្រភេទសត្វស៊ីសាច់ជាអាហារ ដូច្នេះនៅពេលខ្វះចំណីអន្ទង់ធំអាចស៊ីអន្ទង់តូចៗបាន។ កូនអន្ទង់ដាក់ចិញ្ចឹមត្រូវមានទំហំស្មើៗគ្នា និងត្រូវមានចំនួនយ៉ាងច្រើន ២០ក្បាល ក្នុងមួយគីឡូក្រាម ដើម្បីឱ្យកូនអន្ទង់មានអត្រារស់ខ្ពស់។ កូនអន្ទង់ដែលចាប់ពីធម្មជាតិត្រូវថែទាំឱ្យបានល្អមិនត្រូវច្រកក្នុងការ៉ុងទេ ចៀសវាងការធ្វើឱ្យអន្ទង់មានដំបៅ ឬ របកលើដងខ្លួន។



របៀបថែរក្សាកូនអន្ទង់



ការរាប់កូនអន្ទង់



ការថ្លឹងកូនអន្ទង់

## ៩- ប្រភេទអន្ទង់

ប្រភេទអន្ទង់ត្រូវដាក់ចិញ្ចឹមក៏ជាកត្តាសំខាន់មួយដែរ ដោយយើងត្រូវផ្តោតទៅលើតម្រូវការទីផ្សារ និងកម្រិតលូតលាស់ធំធាត់របស់ប្រភេទអន្ទង់នីមួយៗ។ ប្រភេទអន្ទង់ដែលមានលក្ខណៈសមស្របបំផុតក្នុងការចិញ្ចឹម និងដើម្បីតម្រូវការទីផ្សារ គឺអន្ទង់ដំណើប និងអន្ទង់គ្រាវ។



អន្ទង់ដំណើប



អន្ទង់គ្រាវ

### គ- ដង់ស៊ីតេដាក់ចិញ្ចឹម

តាមបទពិសោធន៍អនុវត្តកន្លងមក កូនអន្ទង់ពូជដែលមានទម្ងន់ ២០ក្បាលក្នុងមួយគីឡូក្រាមត្រូវដាក់ចិញ្ចឹមពី ២០០ក្បាល ទៅ ២៥០ក្បាល ក្នុងមួយម៉ែត្រការ៉េទទួលបានអត្រារស់ខ្ពស់ និងផ្តល់ផលក្នុងរយៈពេលខ្លី ។



*ការថ្លឹងកូនអន្ទង់*



*ការរាប់កូនអន្ទង់*

### ឃ- ការដឹកជញ្ជូន និងពេលវេលាលែងកូនអន្ទង់

មតិភាគច្រើនបានយល់ថា អន្ទង់ជាប្រភេទសត្វមានភាពធន់ទ្រាំនឹងមជ្ឈដ្ឋានជុំវិញខ្ពស់ និងកម្រិតអុកស៊ីសែនទាប ដូចនេះមិនបានគិតដល់ការរក្សាគុណភាពកូនអន្ទង់ដែលត្រូវដាក់ចិញ្ចឹម ហើយតែងដឹកជញ្ជូនមិនបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ។ កាលណាកូនអន្ទង់ដឹកជញ្ជូនមិនបានសមស្របអាចធ្វើឱ្យកូនអន្ទង់បាក់កម្លាំងរលាកខ្លួន និងអាចងាប់ ក្រោយពេលដាក់ចូលអាង ឬ ធ្វើឱ្យកូនអន្ទង់បន្ថយពេលស៊ីចំណីនាំឱ្យគ្រិន ឬ ធំធាត់យឺត ។ ដូច្នេះការដឹកជញ្ជូនកូនអន្ទង់ ទោះបីមិនមានអុកស៊ីសែនគ្រប់គ្រាន់ក្តីក៏យើងត្រូវដាក់វាក្នុងបរិមាណមួយសមស្របដែរ ។ ការវេចខ្ចប់កូនអន្ទង់ដើម្បីដឹកជញ្ជូនត្រូវដាក់ក្នុងធុង ឬ ថង់ដែលមានភាពកកិតទាបបំផុត ។ ជាទូទៅកូនអន្ទង់អាចដាក់បាន

ចំនួនច្រើនជាងត្រី ។

ពេលវេលាដាក់កូនអន្ទង់ចូលអាង គួរកំណត់យកពេលរសៀលទើបល្អ។ ការលែងកូនអន្ទង់ត្រូវអនុវត្តដោយការបាចទឹកបញ្ចូលបន្តិចម្តងៗក្នុងធុង ឬ ផង់ដាក់កូនអន្ទង់ ដើម្បីឱ្យកូនអន្ទង់មានលក្ខណៈបន្សាំទៅមជ្ឈដ្ឋានថ្មីបានល្អ ។


*ការដឹកជញ្ជូនកូនអន្ទង់*


*ការថែរក្សាកូនអន្ទង់*


*ការលែងកូនអន្ទង់*

## ៦_ ពេលវេលាដាក់ចិញ្ចឹម

ដោយសារកូនអន្ទង់ពូជបានពីធម្មជាតិ ដូច្នេះអ្នកចិញ្ចឹមទាំងឡាយត្រូវតែរង់ចាំរៀបចំកន្លែងដាក់កូនអន្ទង់ចិញ្ចឹម រហូតដល់រដូវភ្លៀងធ្លាក់ចាប់ពីខែ មិថុនា ដល់ខែ សីហា។ ពេលវេលាដែលសម្បូរកូនពូជអន្ទង់ជាងគេគឺ ខែ កក្កដា និងខែ សីហា។

## ៧_ ប្រភេទចំណីអន្ទង់

ចំណីអាហាររបស់អន្ទង់គឺ កាកសំណល់ត្រីដែលមានតម្លៃថោក ខ្យង វារីសត្វ និងសត្វឥតឆ្អឹងកងដទៃទៀត។ គេអាចលាយជាមួយនឹងកន្ទក់ ម្សៅត្រី ឬ វីតាមីន។ ចំណីត្រូវលាយជាមួយសារធាតុស្អិត ដើម្បីចៀសវាងការខូចគុណភាពទឹកឆាប់រហ័សពេក។

## ក- ប្រភេទចំណី

តាមបទពិសោធន៍កន្លងមក ប្រភេទចំណីដែលត្រូវផ្តល់ឱ្យអន្ទង់ស៊ីរួមមានៈត្រី ឬ ខ្យង ដែលចាប់តាមវាលស្រែ បឹង... និងលាយជាមួយនឹងកន្ទក់ទៅតាមដំណាក់កាលនីមួយៗ។

នៅខែទីមួយៈ ប្រភេទចំណីអន្ទង់ ប្រើប្រភេទត្រីគុណភាពទាបស្រុសជាមួយទឹកក្តៅ ឬ ខ្យងឆៅចិញ្ច្រាំ ដាក់ឱ្យអន្ទង់ស៊ី។

ចាប់ពីខែទីពីរៈ ប្រភេទចំណីអន្ទង់ប្រើកាក សំណល់ត្រីស្រុសជាមួយទឹកក្តៅ ឬ ខ្យងឆៅចិញ្ច្រាំ និងលាយជាមួយកន្ទក់ក្នុងអត្រា មធ្យមត្រី ឬ ខ្យង ៧០ភាគរយ និងកន្ទក់ ៣០ ភាគរយ។ កាកសំណល់ត្រីក្នុងសមាសធាតុ ផ្សំចំណីមិនអាចខ្វះបានទេ តែខ្យង និងកន្ទក់អាចខ្វះបាន។ ប៉ុន្តែការលាយផ្សំចំណីចូលគ្នារវាងត្រី និងកន្ទក់ត្រូវបានប្រើញឹកញាប់ ព្រោះងាយឱ្យអន្ទង់ធំធាត់កាត់បន្ថយប្រាក់ចំណាយ និងអាចទទួលបានប្រាក់ចំណេញច្រើន។



ត្រី



ខ្យង



កន្ទក់

## ៦- ចរិតស៊ីចំណី

អន្ទង់ជាប្រភេទសត្វដែលមានជីវិតក្រាំង ។ នៅក្នុងធម្មជាតិចាប់ពីខែមករា ដល់ខែមីនា អន្ទង់បានចំណាយពេលវេលា " ជីវិតក្រាំង " នៅក្នុងដីដោយប្រើប្រាស់អាហារបម្រុងដែលមាននៅក្នុងខ្លួន។ ហេតុដូច្នេះហើយ អន្ទង់ដែលបានពីធម្មជាតិយកមកចិញ្ចឹមនៅអំឡុងពេលខែ មករា ដល់ខែ មីនា អន្ទង់ក៏មិនស៊ីចំណីដែរ ប៉ុន្តែក៏មិនស្រកទម្ងន់របស់វាទេ។ ទោះបីអន្ទង់ជាប្រភេទសត្វដែលមានភាពធន់នឹងគុណភាពទឹកកខ្វក់ ប៉ុន្តែវាអាចទ្រាំបានក្នុងកម្រិតណាមួយតែប៉ុណ្ណោះ។ ជាក់ស្តែង ក្នុងការចិញ្ចឹមកន្លងមកនៅពេលដែលទឹកចាប់ផ្តើមស្អុយខ្លាំង អន្ទង់បន្ថយកម្រិតស៊ីចំណី ដែលពេលនោះទាមទារឱ្យផ្លាស់ប្តូរទឹកថ្មី បើមិនដូច្នោះទេវានឹងកើតមានជំងឺ និងត្រូវងាប់ ។

មួយខែក្រោយ ចាប់ផ្តើមពីពេលដែលអន្ទង់ចាប់ស៊ីចំណី (ករណីពូជអន្ទង់ចំនួន ៥០ គីឡូក្រាម មានចំនួនមធ្យម ១០០០ក្បាល) ចំណីត្រូវផ្តល់មានចំនួន ២ គីឡូក្រាម ក្នុងមួយថ្ងៃចាប់ពីខែទីពីរ បរិមាណចំណីកើនដល់ ៣ គីឡូក្រាម ក្នុងមួយថ្ងៃ។ តាមការកត់សំគាល់បង្ហាញ ថា ២ ទៅ ៣ថ្ងៃ មុនពេលដល់កម្រិតត្រូវផ្លាស់ប្តូរទឹកការស៊ីចំណីរបស់អន្ទង់បានថយចុះពី ១៥ ភាគរយ ទៅ ២០ភាគរយ ហើយនៅពេលដែលផ្លាស់ប្តូរទឹករួចក្នុងរយៈពេលបីថ្ងៃ អន្ទង់មិនស៊ីចំណីទេ។ នៅរដូវរងា (ពីខែកត្តិក ដល់ខែបុស្ស) អន្ទង់មិនសូវស៊ីចំណីទេគឺ ថយចុះពី ១៥ ភាគរយ ទៅ ២០ ភាគរយដែរ។

អន្ទង់មិនមែនជាសត្វដែលត្រូវស៊ីចំណីជាប្រចាំទេ រយៈពេល ២-៣ថ្ងៃ ទើបវាស៊ីចំណីម្តង ដូចករណីសត្វពស់ថ្លាន់ដែរ។ តាមការពិនិត្យឃើញជាក់ស្តែង ពេលផ្តល់ចំណីរៀងរាល់ថ្ងៃ គឺអន្ទង់បានផ្លាស់ប្តូរវេនគ្នាមកស៊ីចំណី មិនមែនអន្ទង់ក្នុងអាងចិញ្ចឹមទាំងអស់មកស៊ីចំណីព្រមគ្នាទេ។ អន្ទង់ជាប្រភេទសត្វស៊ីសាច់ជាអាហារ ដូច្នេះអន្ទង់ធំអាចស៊ីអន្ទង់តូចជាអាហារបាននៅពេលវាឃ្លានខ្លាំង ជាហេតុបណ្តាលឱ្យមានការបាត់បង់ចំនួនអន្ទង់

រួមផ្សំនឹងការបាត់បង់ដោយជំងឺ ឬ ស្លាប់ដោយកត្តាផ្សេងៗ។

បទពិសោធន៍របស់កសិករ **ខឹម សារិទ្ធ** បានបង្ហាញថា កូនអន្ទង់ដែលចាប់ពីធម្មជាតិយកមកដាក់ចិញ្ចឹមរយៈពេលមួយសប្តាហ៍ទើបចាប់ផ្តើមស៊ីចំណីដោយប្រើចំណីចំនួន ២ គីឡូក្រាម ក្នុងមួយថ្ងៃ អស់រយៈពេលមួយខែ ទើបបង្កើនបរិមាណចំណីដល់ចំនួន ៣ គីឡូក្រាម ក្នុងមួយថ្ងៃ (ករណីកូនអន្ទង់ចំនួន ៥០ គីឡូក្រាម មានចំនួនមធ្យម ១០០០ ក្បាល) ហើយការចិញ្ចឹម អន្ទង់នេះ ជាទូទៅចាប់ផ្តើមនៅខែសីហា ហើយប្រមូលផលនៅខែមីនា ដែលមានរយៈពេល ៨ ខែ។

### គ- ពេលវេលាផ្តល់ចំណី

ពេលល្ងាចជាពេលវេលាល្អសម្រាប់ការផ្តល់ចំណី។ នៅពេលទឹកក្នុងអាងឡើងស្អុយ និងនៅពេលផ្លាស់ប្តូរទឹកភ្លាមៗ អន្ទង់មិនស៊ីចំណីទេ ក្រោយរយៈពេលបីថ្ងៃទើបអន្ទង់ចាប់ស៊ីចំណី ព្រោះនៅពេលប្តូរទឹកភ្លាមអន្ទង់សប្បាយនឹងទឹកថ្មី។

### ឃ- របៀបផ្តល់ចំណី

យើងមិនត្រូវដាក់ចំណីអន្ទង់ដោយបោះចូលទៅក្នុងទឹកផ្ទាល់ទេ គឺត្រូវរៀបចំឱ្យមានកញ្ច្រែងព្យួរប៉ប្រិះផ្ទៃទឹក។ នៅពេលផ្តល់ចំណីយើងគ្រាន់តែដាក់ចំណីនៅលើកញ្ច្រែង ហើយចងព្យួរប៉ប្រិះទឹកជាការស្រេច ពេលនោះកូនអន្ទង់នឹងងើបមកស៊ីចំណី ដោយខ្លួនឯង។ ចំពោះទំហំអាងរៀបរាប់ខាងលើគួរដាក់កញ្ច្រែងចំណីឱ្យបានយ៉ាងតិចបីកន្លែងផ្សេងៗគ្នា។







*ត្រីស្រុះទឹកក្ដៅរួច* *សកម្មភាពដាក់ចំណី* *សកម្មភាពអន្ទង់ស៊ីចំណី*

## ៨. ការតាមដានគុណភាពទឹក និងការផ្លាស់ប្ដូរទឹក

ការតាមដានសម្រាប់ការផ្លាស់ប្ដូរទឹកមានលក្ខណៈងាយស្រួលគឺ តាមរយៈអន្ទង់បន្ថយស៊ីចំណី។ ទឹកស្អុយពេកអន្ទង់មិនស៊ីចំណីទេ។ ដូច្នេះ វាជាសញ្ញាបង្ហាញឱ្យយើងត្រូវធ្វើការផ្លាស់ប្ដូរទឹក។ ការផ្លាស់ប្ដូរទឹកជាទូទៅ គឺនៅរៀងរាល់១០ថ្ងៃម្ដង ដោយបង្ហូរតាមបំពង់ទឹកដែលបានរៀបចំរួចជាស្រេច។



*ប្រភេទទឹកស្អុយដែលត្រូវប្ដូរទឹកចេញ*



*ប្រភេទទឹកល្អដែលមានលក្ខណៈសមស្រប*

## ៩. ជំងឺអន្ទង់

តាមបទពិសោធន៍កន្លងមក អន្ទង់ចិញ្ចឹមនៅអំឡុងខែមករា កុម្ភៈ និងមីនា ភាគច្រើនសង្កេតឃើញមានកើតដំបៅ តែក៏មិនទាន់មានការសន្និដ្ឋានថា អន្ទង់កើតមានជំងឺដោយការប្រែប្រួលអាកាសធាតុ ឬ ការប៉ះទង្គិចគ្នា ឬ ខាំគ្នា។ ការព្យាបាល គឺប្រើដើមត្រស់កាត់ជាកង់ៗត្រាំទៅក្នុងទឹក ដើម្បីឱ្យចេញជ័រខ្មៅៗរយៈពេលពី ១៥-២០ថ្ងៃ នឹងឃើញអន្ទង់បានជាសះស្បើយវិញ។

## ១០. ការប្រមូលផល

ដូចបានរៀបរាប់ខាងលើរយៈពេលចិញ្ចឹមអន្ទង់មានពី ៦-៨ ខែ។ ដោយសារនៅរដូវប្រាំងក្នុងចន្លោះពេលពីខែ មករា ដល់ខែ មីនា អន្ទង់ត្រូវរស់នៅក្នុងជីវិតក្រាំងក្នុងដីដែលធ្វើឱ្យលំបាកក្នុងការនេសាទ ដូច្នេះក្នុងចន្លោះពេលនេះ អន្ទង់មានតម្លៃខ្ពស់ជាងគេជារៀងរាល់ឆ្នាំ។ ដូចនេះ ការប្រមូលផលអន្ទង់ចិញ្ចឹមភាគច្រើនស្ថិតក្នុងខែ មករា កុម្ភៈ និងខែ មីនា។



*ការប្រមូលផលក្នុងអាង*



*ការប្រមូលផលក្នុងអាង*

## ១១. ការវិភាគសេដ្ឋកិច្ច

ក្នុងការសិក្សាផលចំណេញនេះ យើងខ្ញុំសូមលើកមកវិភាគមិនត្រឹមតែលើប្រាក់ចំណូលទេ គឺថែមទាំងលើទិដ្ឋភាពផ្សេងៗទៀត ដែលនឹងមានរៀបរាប់ក្នុងចំណុច

សន្និដ្ឋាន។ ការវិភាគប្រាក់ចំណេញលើករណីចិញ្ចឹមរបស់កសិករ **ខឹម សារិទ្ធ** នៅភូមិរហាលសួង ឃុំព្រែកនរិន្ទ ស្រុកឯកភ្នំ ខេត្តបាត់ដំបង។

**ការគណនាបរិមាណចំណី**

ករណីសិក្សាកូនអន្ទង់ពូជ ចំនួន ៥០ គីឡូក្រាម មានចំនួនមធ្យម ១០០០ក្បាល ហើយរយៈពេលចិញ្ចឹម ៨ ខែ មានចំនួន ២៤០ថ្ងៃ (ពីខែសីហា ដល់ខែ មីនា) ។

**រយៈពេលដែលអន្ទង់មិនស៊ីចំណី : សរុប ១៣៩ ថ្ងៃ**

-ក្រោយពេលដាក់កូនអន្ទង់ អន្ទង់មិនស៊ីចំណីមាន ៧ថ្ងៃ

-នៅខែទី ១ អន្ទង់មិនស៊ីចំណីមាន ៦ថ្ងៃ

-ចាប់ពីខែទី ២ ដល់ទី៨ អន្ទង់មិនស៊ីចំណីមាន ១២៦ ថ្ងៃ

**រយៈពេលដែលអន្ទង់ស៊ីចំណីថយចុះ**

-នៅខែទី១ មានចំនួន ៦ថ្ងៃ ដែលមានអាត្រាផ្តល់ចំណីតែ ១,៦៥ គីឡូក្រាម ក្នុងមួយថ្ងៃ

សរុបបរិមាណចំណី ៦ថ្ងៃ x ១,៦៥ គីឡូក្រាម = ៩,៩ គីឡូក្រាម (ត្រី ឬ ខ្យងសុទ្ធ)

-នៅខែទី២ ដល់ទី៥ មានចំនួន ៣៦ថ្ងៃ ដែលមានអាត្រាផ្តល់ចំណីតែ ២,៥ គីឡូក្រាម ក្នុងមួយថ្ងៃ

សរុបបរិមាណចំណី ៣៦ ថ្ងៃ x ២,៥ គីឡូក្រាម = ៩០ គីឡូក្រាម (ត្រី ឬ ខ្យង ចំនួន ៦៣ គីឡូក្រាម និងកន្ទក់ ចំនួន ២៧ គីឡូក្រាម )

**រយៈពេលដែលអន្ទង់ស៊ីចំណីពេញលេញ**

-នៅខែទី ១ មានចំនួន ១១ថ្ងៃ ដែលអាត្រាផ្តល់ចំណីមាន ២ គីឡូក្រាម ក្នុងមួយថ្ងៃ

សរុបបរិមាណចំណី ១១ថ្ងៃ x ២ គីឡូក្រាម= ២២ គីឡូក្រាម (ត្រី ឬ ខ្យងសុទ្ធ)

-នៅខែទី ២ ដល់ទី៥ មានចំនួន ៤៨ថ្ងៃ ដែលអាត្រាផ្តល់ចំណី ៣ គីឡូក្រាម ក្នុងមួយថ្ងៃ

សរុបបរិមាណចំណី ៤៨ថ្ងៃ x ៣ គីឡូក្រាម= ១៤៤ គីឡូក្រាម ( ត្រី ឬ ខ្យង ចំនួន ១០០,៨ គីឡូក្រាម និងកន្ទក់ ចំនួន ៤៣,២ គីឡូក្រាម )

ដូច្នេះការចិញ្ចឹមរយៈពេល ៨ខែ អន្ទង់ត្រូវការបរិមាណចំណីចំនួន ២៦៥,៩ គីឡូក្រាម ក្នុងនោះត្រី ឬ ខ្យងចំនួន ១៩៥,៧ គីឡូក្រាម និងកន្ទក់ ចំនួន ៧០,២ គីឡូក្រាម ។

**ការវិភាគសេដ្ឋកិច្ច**

**ចំណាយ**

-ពូជអន្ទង់ ចំនួន ៥០ គីឡូក្រាម x ៤៥០០រៀល = ២២៥.០០០រៀល

-ត្រី ឬ ខ្យង ចំនួន ១៩៥,៧ គីឡូក្រាម x ១៥០០រៀល=២៩៣.៥៥០រៀល

-កន្ទក់ ចំនួន ៨២,៨ គីឡូក្រាម x ៧៥០រៀល=៥២.៦៥០រៀល

-សម្ភារៈសាងសង់អាង ចំនួន ១៥០.០០០រៀល ( ប្រើបានរយៈពេល ២ ទៅ៣ឆ្នាំ)

សរុបចំណាយ **៧២១.២០០ រៀល**

**ចំណូល**

អន្ទង់ពេលប្រមូលផលមានចំនួន ១០០ គីឡូក្រាម បានន័យថាកើនមួយជាពីរ ព្រោះ ពេលដាក់ចិញ្ចឹមអន្ទង់មានទម្ងន់សរុប ៥០ គីឡូក្រាម ។ តម្លៃលក់ចេញជាមធ្យម ១២ ០០០រៀលក្នុង ១ គីឡូក្រាម បានន័យថាកើនជាង ២,៥ ដង ដូច្នេះ ប្រាក់ចំណូលគឺ : ១០០ គីឡូក្រាម x ១២.០០០រៀល = ១ ២០០.០០០រៀល

**ចំណេញ**

១.២០០.០០០រៀល - ៧២១ ២០០រៀល = **៤៧៨.៨០០រៀល**

## ១២. ការសន្និដ្ឋាន

ឆ្លងតាមបទពិសោធន៍អស់រយៈពេលបួនឆ្នាំ នៃការចិញ្ចឹមអន្ទង់នេះ និងតាមការវិភាគផលសេដ្ឋកិច្ច យើងខ្ញុំសូមធ្វើការសន្និដ្ឋានដូចខាងក្រោម :

-ចំពោះប្រជានេសាទ កូនអន្ទង់ពូជអាចរកបានដោយខ្លួនឯង និងលក់បានតម្លៃថោក តែនៅពេលដែលគាត់ដាក់ចិញ្ចឹមបំប៉នបន្ថែមនោះ តម្លៃ និងទម្ងន់ត្រូវកើនជាពីរ ឬ បីដង ។

-រូបភាពនៃការចិញ្ចឹមមានលក្ខណៈងាយដែលអាចទទួលយកទៅអនុវត្តបន្តបាន

-ផ្តល់ការងារដល់សមាជិកគ្រួសារ ជាពិសេសស្ត្រីក៏អាចធ្វើការងារនេះបានដែរ

-ផ្ទៃដី និងពេលវេលាទំនេរត្រូវបានប្រើ និងក្លាយជាប្រាក់ចំណូល

-បង្កើនបទពិសោធន៍វិជ្ជាជីវៈ និងអាចក្លាយជាគ្រូបង្គោលក្នុងសកម្មភាពអភិវឌ្ឍវារីវប្បកម្ម

-ប្រើប្រាស់ត្រីដែលមានគុណភាពទាបឱ្យក្លាយទៅជាសាច់សត្វមានតម្លៃខ្ពស់

-ប្រើប្រាស់សម្ភារៈដែលមិនមានប្រយោជន៍សេដ្ឋកិច្ចមកជាមធ្យោបាយបង្កើនប្រាក់ចំណូល

-បង្កើនប្រាក់ចំណូលលើកស្ទួយសេដ្ឋកិច្ចគ្រួសារ ។

ដូច្នេះយើងខ្ញុំសូមសំណូមពរដូចខាងក្រោម :

-ប្រជាកសិករ ត្រូវសាកល្បងចិញ្ចឹមអន្ទង់តាមមេរៀនដូចបានរៀបរាប់ខាងលើ ដោយប្រើប្រាស់ធនធានដែលនៅជុំវិញឱ្យមានតម្លៃ និងបង្កើនប្រាក់ចំណូល ។

-មន្ត្រីជំនាញជលផលទាំងអស់ ត្រូវរួមគ្នាស្រាវជ្រាវលើការភ្ញាស់កូនអន្ទង់ ដើម្បីបំពេញតម្រូវការចិញ្ចឹមកាត់បន្ថយការចាប់ពីធម្មជាតិ ៕

## អ្នកឧបត្ថម្ភបោះពុម្ពផ្សាយ ឯកឧត្តម ឧកញ៉ា ឡុង ហ៊ីង
## ទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន




នាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម នៃរដ្ឋបាលជលផល

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

អាសយដ្ឋានលេខ ១៨៦ មហាវិថីព្រះនរោត្តម ប្រអប់សំបុត្រ ៨៣៥

រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារ (៨៥៥) ២៣ ៩៩៦ ៣៨០